# ប្រព័ន្ធសុចរិតភាពសាជីវកម្ម (CIS)

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

ប្រព័ន្ធសុចរិតភាពសាជីវកម្ម(CIS) គឺជាផ្នែកមួយដ៏សំខាន់ក្នុងការធានាឱ្យមានសុចរិតភាពនៅក្នុងការប្រកបអាជីវកម្ម។ ការអនុវត្តនូវប្រព័ន្ធនេះបានបង្ហាញនូវការជួយសន្សំសំចៃ និងកាត់បន្ថយនូវសាច់ញាតិនិងបក្សពួកនិយម ទំនាស់ផលប្រយោជន៍ និងអំពើពុករលួយ ។ បច្ចុប្បន្ន អង្គការតម្លាភាពកម្ពុជា បាននិងកំពុងផ្ដល់ជាជំនួយបច្ចេកទេសដោយមិនគិតថ្លៃ ដល់ក្រុមហ៊ុនទាំងឡាយដើម្បីអនុវត្តប្រព័ន្ធសុចរិតភាពសាជីវកម្មនេះ។

សុចរិតភាពធុរៈកិច្ច ជាញឹកញាប់ត្រូវបានគេមើលឃើញ ថាជាសមិទ្ធផលនៃការដឹកនាំប្រកបដោយសីលធ៌ម ការគោរពប្រតិបត្តិតាមនីតិវិធី និងបទបញ្ញាតឹងរឹងដែលបង្ការ និងដាក់ពិន័យចំពោះការប្រព្រឹត្តខុស។ ធាតុផ្សំទាំងអស់នេះ សុទ្ធតែមានសារៈសំខាន់ ប៉ុន្តែធាតុផ្សំតែឯងណាមួយនៃធាតុផ្សំទាំងនេះ នឹងមិនអាចមានឥទ្ធិពលគ្រប់គ្រាន់ សម្រាប់ដោះស្រាយបានជានិច្ចនូវហានិភ័យនានានៃអំពើពុករលួយ ដែលមានសភាពប្រទាក់ប្រទងគ្នា ដែលក្រុមហ៊ុនជួបប្រទះបានឡើយ។ ការអនុវត្តនូវប្រព័ន្ធសុចរិតភាពសាជីវកម្ម(CIS) អាចដោះស្រាយ និងទប់ស្កាត់នូវហានិភ័យទាំងនេះបាន។ អង្គការតម្លាភាពកម្ពុជារីករាយផ្ដល់ការគាំទ្រដល់ក្រុមហ៊ុនទាំងឡាយដើម្បីអនុវត្តនូវប្រព័ន្ធសុចរិតភាពសាជីវកម្មនេះ។

ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីលេខាធិការដ្ឋាននៃអង្គការតម្លាភាពអន្តរជាតិ និងអង្គការតម្លាភាព នៅប្រទេសម៉ាឡេស៊ី អង្គការតម្លាភាពកម្ពុជាអាចផ្ដល់ជូនក្រុមហ៊ុននូវការគាំទ្រនៅក្នុងជំហាននីមួយៗ នៃជំហានទាំងប្រាំមួយ ក្នុងដំណើរការអនុវត្តប្រព័ន្ធនេះ។ ប្រព័ន្ធសុចរិតភាពសាជីវកម្មល្អ នឹងបង្កើតនូវរចនាសម្ព័ន្ធអភិបាលកិច្ចផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពដែលអាចឱ្យក្រុមហ៊ុនកាត់បន្ថយនូវឱកាសសម្រាប់សាច់ញាតិនិងគ្រួសារនិយម ទំនាស់ផលប្រយោជន៍ និងអំពើពុករលួយ។ វាក៏អាចជួយទប់ស្កាត់កុំឱ្យបុគ្គលិកក្រុមហ៊ុនប្រព្រឹត្តអំពើពុករលួយ តាមរយៈការដាក់ចេញនូវគោលនយោបាយ និងនីតិវិធី ច្បាស់លាស់ទៅលើវិធានការឆ្លើយតប នៅពេលដែលពួកគេជួបប្រទះនឹងអំពើពុករលួយ។ បច្ចុប្បន្ននេះ អង្គការតម្លាភាពកម្ពុជា ផ្ដល់ជំនួយផ្នែកបច្ចេកទេសដោយឥតគិតថ្លៃដល់ក្រុមហ៊ុន ដើម្បីអនុវត្តនូវប្រព័ន្ធសុចរិតភាពសាជីវកម្មនេះ។ សម្រាប់ចំណុចសង្ខេបនៃដំណើរការអនុវត្តប្រព័ន្ធនេះ សូមមើលផ្នែក សុចរិតភាព ខាងក្រោម។

## ការផ្លាស់ប្តូរបរិយាកាសធុរៈកិច្ចនៅកម្ពុជា

បរិយាកាសធុរៈកិច្ចនៅកម្ពុជាមានការផ្លាស់ប្តូរយ៉ាងច្រើននៅក្នុងឆ្នាំ២០១៥។ ការផ្លាស់ប្តូរមួយចំនួនដែលគួរឱ្យកត់សម្គាល់ រួមមានការបង្កើតឱ្យមានប្រព័ន្ធអនឡាញរបស់ក្រសួងពាណិជ្ជកម្ម (MoC) សម្រាប់វិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញដើម (COO) និងការចុះបញ្ជីពាណិជ្ជកម្ម។ លើសពីនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារ (GDT) បានចេញសេចក្ដីប្រកាស កាលពីខែវិច្ឆិកា ឆ្នាំ២០១៥ ថាអគ្គនាយកដ្ឋាននេះ នឹងលុបចោលនូវពន្ធរបបម៉ៅការ ហើយងាកទៅរករបបពន្ធដែលពិតប្រាកដ។ ការផ្លាស់ប្តូរទាំងនេះ គឺជាផ្នែកមួយនៃការជួយជម្រុញពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតឱ្យមានជាទម្រង់ជាក់លាក់សម្រាប់វិស័យឯកជន ដែលនឹងតម្រូវឱ្យក្រុមហ៊ុន មានការប្ដេជ្ញាគោរពតាម និងជម្រុញឱ្យពួកគេប្រែក្លាយពីអាជីវកម្មក្រៅផ្លូវការទៅជាអាជីវកម្មផ្លូវការ។ ប្រទេសកម្ពុជា កំពុងតែផ្លាស់ប្តូរទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ដែលនេះនឹងកាត់បន្ថយនូវជំនួយបរទេស នាំទៅរកការកើនឡើងនូវតម្រូវការរបស់រដ្ឋាភិបាលក្នុងការប្រមូលពន្ធ។ បន្ថែមពីលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាសកលនិងក្នុងតំបន់ដូចជាដៃគូពាណិជ្ជកម្មអន្តរប៉ាស៊ីហ្វិក(TTP) និងសមាគមសេដ្ឋកិច្ចអាស៊ាន(AEC) ការផ្លាស់ប្តូរនេះនឹងបង្កើតនូវបរិយាកាសអាជីវកម្មប្រកួតប្រជែងកាន់តែខ្លាំងឡើងៗ និងការ

ផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើការប្រតិបត្តិតាម។ ប្រព័ន្ធសុចរិតភាពសាជីវកម្ម គឺជាមធ្យោបាយចាប់ផ្តើមដ៏ល្អមួយ សម្រាប់ឱ្យក្រុមហ៊ុនធានាឱ្យបាននូវជំហររឹងមាំទៅថ្ងៃអនាគត។

## អំពីប្រព័ន្ធសុចរិតភាពសាជីវកម្ម

ក្នុងការអនុវត្តប្រព័ន្ធសុចរិតភាពសាជីវកម្មសម្រាប់ក្រុមហ៊ុន អង្គការតម្លាភាពកម្ពុជានឹងធ្វើការណែនាំអំពីជំហាននីមួយៗ ដើម្បីធានាឱ្យមានការអនុវត្តផែនការដោយរលូន។ ដំណើរការនៃការអនុវត្តប្រព័ន្ធសុចរិតភាពសាជីវកម្ម មាន៦ជំហានដូចខាងក្រោម៖




១) ក្រុមហ៊ុនចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការយល់ព្រមប្តេជ្ញាចិត្តអនុវត្តនូវគម្រោងប្រព័ន្ធសុចរិតភាព

២) ការវាយតម្លៃរកហានិភ័យ នឹងធ្វើឡើងសម្រាប់ក្រុមហ៊ុននីមួយៗ ដោយវាយតម្លៃលើគោលនយោបាយ និងនីតិវិធីដែលមានស្រាប់ និងចំណុចដែលមានហានិភ័យខ្ពស់បំផុត សម្រាប់ក្រុមហ៊ុន។ គំនូសពីងពាងហានិភ័យ នឹងត្រូវបានបង្កើតឡើងដើម្បីកំណត់ឱ្យឃើញនូវហានិភ័យទាំងអស់នោះ។

៣) សម្ភារៈនិងគោលនយោបាយសម្រាប់វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងក្រោមការសហការជាមួយបុគ្គលិកគោលរបស់ក្រុមហ៊ុន សំដៅពង្រឹងគោលនយោបាយ នីតិវិធី និងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ក្រុមហ៊ុន។ ជាទូទៅ វគ្គបណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិកទូទៅ នឹងធ្វើឡើងដើម្បីបង្កើនការយល់ដឹងពីសុចរិតភាពសាជីវកម្មឱ្យកាន់តែប្រសើរឡើង។

៤) ក្រុមហ៊ុនស្នើសុំការយល់ព្រមពីក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការកែប្រែ និងរៀបចំឱ្យបុគ្គលិកធ្វើការអនុវត្ត។

៥) ក្រុមហ៊ុនអនុវត្តគោលនយោបាយ និងនីតិវិធីដែល បានព្រមព្រៀងគ្នាខាងលើ។

៥) ធ្វើការវាយតម្លៃលើគោលនយោបាយ និងនីតិវិធី របស់ក្រុមហ៊ុនសារជាថ្មីម្តងទៀតដោយក្រឡេកមើលទៅលើភាពជោគជ័យនៃការអនុវត្ត និងវិធីក្នុងការពង្រឹងក្របខ័ណ្ឌការងារបន្ទាប់ទៀត។

អង្គការតម្លាភាពកម្ពុជាអាចបន្តផ្តល់ការគាំទ្រដល់ក្រុមហ៊ុនបន្ទាប់ពីការអនុវត្តនូវប្រព័ន្ធសុចរិតភាពសាជីវកម្មនេះ និងបត់បែនតាមតម្រូវការរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនទាំងឡាយ ត្រូវបានណែនាំក្នុងការចាត់តាំងឱ្យមានប្រធានផ្នែកសុចរិតភាពដើម្បីបម្រើការជាមន្ត្រីទំនាក់ទំនង និងធ្វើការងារបន្ត បន្ទាប់ពីប្រព័ន្ធសុចរិតភាពសាជីវកម្មត្រូវបានអនុវត្តចប់សព្វគ្រប់។ ជាទូទៅ ដំណើរការអនុវត្តចំណាយពេលពីចន្លោះប្រាំមួយទៅប្រាំបួនខែ ផ្អែកទៅលើសមត្ថភាព និងទំហំនៃក្រុមហ៊ុន។





© 2015 Transparency International Cambodia. All rights reserved.

## រឿងជោគជ័យរបស់ប្រទេសម៉ាឡេស៊ី

ប្រព័ន្ធសុចរិតភាពសាជីវកម្ម ត្រូវបានណែនាំឱ្យស្គាល់ ដំបូងបង្អស់ ដោយកម្មវិធីសុចរិតភាពធុរៈកិច្ច របស់អង្គការតម្លាភាពម៉ាឡេស៊ី។ បន្ទាប់ពីតម្រូវការនូវប្រព័ន្ធសុចរិតភាពសាជីវកម្មមានការកើនឡើងដ៏គួរឱ្យកត់សម្គាល់ អាជ្ញាប័ណ្ណប្រព័ន្ធសុចរិត-ភាពសាជីវកម្មត្រូវបានទិញ ដោយ Trident Integrity ដែលផ្តល់នូវប្រព័ន្ធសុចរិតភាពសាជីវកម្មតាមរយៈការផ្តល់កិច្ចប្រឹក្សា។ ការប៉ាន់ប្រមាណពីធនាគារពិភពលោកបង្ហាញថា អំពើពុករលួយបានបន្ថែម២៥%លើថ្លៃកិច្ចសន្យាលទ្ធកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ បញ្ហានេះអាចដោះស្រាយបានតាមរយៈប្រព័ន្ធសុចរិតភាពសាជីវកម្ម។ ឧទាហរណ៍មួយ ពីប្រទេសម៉ាឡេស៊ី នឹងអាចបង្ហាញពីសក្តានុពលរបស់ប្រព័ន្ធនេះ។ ក្រុមហ៊ុន Perbadanan Kemajuan Negeri Selangor (PKNS) បង្ហាញឱ្យឃើញថាក្រុមហ៊ុននេះអាចសន្សំប្រាក់ប្រមាណជា១២៥លានសហរដ្ឋអា-មេរិកក្នុងរយៈពេល៤ឆ្នាំ តាមរយៈការពង្រឹងនូវនីតិវិធី និងការអនុវត្តកត្តិកាសញ្ញាសុចរិតភាព។ សម្រាប់ក្រុមហ៊ុនដែលស្ថិតក្នុងបរិយាកាសធុរៈកិច្ចពុករលួយដូចជានៅប្រទេសកម្ពុជា ផលចំណេញដែលនឹងទទួលបានពីប្រព័ន្ធនេះរឹតតែមានច្រើនសន្ធឹកសន្ធាប់។

## ផលប្រយោជន៍នៃការអនុវត្តប្រព័ន្ធសុចរិតភាពសាជីវកម្ម

ប្រព័ន្ធសុចរិតភាពសាជីវកម្ម នឹងត្រូវបានប្រើប្រាស់ជាចំនុចគោល និងជាគោលការណ៍ណែនាំសម្រាប់បុគ្គលិក ពីរបៀបឆ្លើយតប នៅពេលដែលពួកគេជួបប្រទះនឹងបញ្ហាពុករលួយ។ ប្រព័ន្ធនេះនឹងជួយផ្តល់អំណាចដល់បុគ្គលិកក្នុងការបដិសេធចំពោះការទាមទារប្រាក់ក្រៅផ្លូវការ និងបង្កើតនូវវប្បធម៌សុចរិតភាពក្នុងក្រុមហ៊ុន។ សម្រាប់ថ្នាក់គ្រប់គ្រងក្រុមហ៊ុន ប្រព័ន្ធសុចរិតភាពសាជីវកម្មនេះ គឺជាវិធីដ៏សំខាន់មួយ ក្នុងការផ្ញើសារទៅកាន់បុគ្គលិករបស់ពួកគេឱ្យដឹង ថាសុចរិតភាព គឺជាចំណុចអាទិភាពមួយ។ ការកែតម្រូវគំរូនិងទំលាប់ចាស់ជាទូទៅមានការពិបាក ។ សម្រាប់ហេតុផលនេះ ប្រព័ន្ធសុចរិតភាពសាជីវកម្មអាចផ្តល់ឱ្យក្រុមហ៊ុននូវការចាប់ផ្តើមថ្មី ដែលអាចដោះស្រាយនូវទំនាក់ទំនងដែលបង្កជាបញ្ហា ជាពិសេសទាក់ទងនឹងការផ្តល់អំណោយ និងបញ្ហាបដិសណ្ឋារកិច្ច។ ប្រទេសកម្ពុជាមានការរីកចម្រើននៅក្នុងការវិនិយោគដោយផ្ទាល់ពីបរទេស ពី១២០០លានសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៣ ទៅ១៧០០លានដុល្លាសហរដ្ឋអាមេរិកនៅឆ្នាំ ២០១៤[1]។ ៦០%នៃការវិនិយោគដោយផ្ទាល់ពីបរទេសលំហូរមកកម្ពុជា គឺមកពីប្រទេសចិន និងរដ្ឋជាសមាជិកអាស៊ានវិនិយោគដោយផ្ទាល់ពីបរទេសលំហូរមកពីសហរដ្ឋអាមេរិក ហើយប្រទេសសហគមន៍អឺរ៉ុប នៅមានកម្រិតទាបនៅឡើយ[2]។ កត្តាសំខាន់មួយ ដែលធ្វើឱ្យលំហូរវិនិយោគដោយផ្ទាល់ពីប្រទេសសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិកមានកម្រិតទាប គឺមកពីអំពើពុករលួយ។ ហានិភ័យនៃអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេយល់ឃើញថាមានកម្រិតខ្ពស់ជាងបើប្រៀបធៀបទៅនឹង បណ្តាប្រទេសផ្សេងៗនៅរដ្ឋជាសមា-ជិកអាស៊ាន[3]។ ដើម្បីទាក់ទាញនូវការវិនិយោគបន្ថែមទៀត ពីសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក តម្រូវការនៃការប្រតិបត្តិតាម ត្រូវតែពង្រឹង ហើយប្រព័ន្ធសុចរិតភាពសាជីវកម្មអាចធានាចំពោះអ្នកវិនិយោគបរទេសថា ហានិភ័យនៃអំពើពុករលួយត្រូវបានគ្រប់គ្រង យ៉ាងមានប្រសិទ្ធភាព។

សម្រាប់ព័ត៌មានបន្ថែម និងដើម្បីចាប់ផ្តើមនូវប្រព័ន្ធសុចរិតភាពសម្រាប់ក្រុមហ៊ុនរបស់អ្នក សូមទំនាក់ទំនងមកអ៊ីម៉ែល matsstridsman@ticambodia.org.

[1] ASEAN Investment Report 2015, ASEAN Secretariat and
[2] Ibid
[3] ASEAN Business Outlook Survey 2015, AmCham Singapore in collaboration with U.S Chamber of Commerce, 2015


© 2015 Transparency International Cambodia. All rights reserved.